# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម





**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**


# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៧៥

បន្ទាប់ពីអង្គជំនុំជម្រះតុលាការកំពូល បានប្រកាសសាលដីកាលើសំណុំរឿង០០២ វគ្គ១ កាលពីសប្តាហ៍មុនរួចមក នាសប្តាហ៍នេះ កិច្ចដំណើរការនីតិវិធីសវនាការលើសំណុំរឿង០០២ វគ្គ២ បានចាប់ផ្តើមឡើងវិញ។ ក្នុងអំឡុងពេលសវនាការរយៈពេលបួនថ្ងៃ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មរបស់សាក្សីចំនួនបីរូប និងដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូប ជាពិសេសពាក់ព័ន្ធផ្នែកជំនុំជម្រះស្តីពីតួនាទីរបស់ជនជាប់ចោទ។ សាក្សីដំបូងគេក្នុងសប្តាហ៍នេះ គឺអ្នកស្រី **ប៊ិច បឿន** បានប្រាប់តុលាការឲ្យដឹងពីកិច្ចប្រជុំនានាដែលអ្នកស្រីបានចូលរួម ដោយមានវត្តមានរបស់លោក **នួន ជា** និងលោក ***ខៀវ សំផន*** ហើយនិងបានផ្តល់សក្ខីកម្មពីការបញ្ជូនខ្លួនគាត់ទៅកាន់ការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំង នៅក្រោយពេលដែលស្វាមីរបស់អ្នកស្រីត្រូវបានចាប់ខ្លួន។ សាក្សីបន្ទាប់ដែលបានឡើងផ្តល់សក្ខីកម្មក្នុងសប្តាហ៍ គឺលោក **សេង លីធេង** ដែលជាក្មួយប្រុសរបស់ **ប៉ុល ពត** បានធ្វើការជាប់នឹង **ប៉ុល ពត** ពេញមួយរបបនោះតែម្តង។ អ្នកផ្តល់កសក្ខីកម្មទីបីក្នុងសប្តាហ៍នេះ គឺជាដើមបណ្តឹងរដ្ឋប្បវេណី អ្នកស្រី ***ខៀវ នៀប*** បានផ្តល់សក្ខីកម្មអំពីការបានឃើញលោក ***ខៀវ សំផន*** កំពុងចែកក្រម៉ាពណ៌ខៀវនិងស ទៅឲ្យជនភៀសខ្លួនថ្មីៗដែលទើបនឹងរត់ចេញពីភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៨។ ដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់ដែលមានអត្តលេខ **2-TCCP-1063** ក៏បានផ្តល់សក្ខីកម្មផងដែរដោយបានប្រើប្រាស់រហស្សនាមការពារ ស្តីពីការបានឃើញលោក ***ខៀវ សំផន*** កំពុងចុះចែកអាហារ និងសម្ភារផ្គត់ផ្គង់ជាច្រើននៅឯផ្សារមួយកន្លែង។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានរម្លឹកថា លោក ***ខៀវ សំផន*** បានផ្តល់សុន្ទរកថាមួយ ស្តីពីតម្រូវការចាំបាច់ក្នុងការកំចាត់បញ្ញវន្ត។ សាក្សីចុងក្រោយក្នុងសប្តាហ៍នេះ គឺលោក **ស៊ីន អ៊ឹង** ដែលជាញាតិសាច់ឆ្ងាយរបស់លោក

**សៅ ភឹម** បានធ្វើការជាកងការពារឲ្យលោក **សៅ ភឹម** ក្នុងអំឡុងពេលនៃរបបនោះ បានផ្តល់សក្ខីកម្មស្តីពីទំនាក់ទំនងរវាងភូមិភាគបូព៌ា និងភូមិភាគមជ្ឈិម។ មានសំណួរជាច្រើនដែលត្រូវបានកត់សម្គាល់ថា ជាសំណួរក្រៅវិសាលភាពនៃសំណុំរឿង០០២ វគ្គ២ ជាពិសេសពាក់ព័ន្ធនឹងអ្វីដែលត្រូវបានគេស្គាល់ថា ជាការផ្លាស់ទីលំនៅរបស់ប្រជាជនដំណាក់កាលទីបី  បាននាំឲ្យមានការជំទាស់ជាច្រើនលើកច្រើនសាពីសំណាក់ក្រុមមេធាវីការពារក្តីក្នុងសប្តាហ៍នេះផងដែរ។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ម៉ាយខល ចេន (Michael Chen), ហាន់ណា ដេយឆ៍ (Hanna Daych), ខេតលីន កាហ្វព្រៀ (Caitlin McCaffrie), និន វុទ្ធី, លូវីស រេតវ៉ាយលើ (Louise Rettweiler), តាយ លីណា, ធំ ស្លាពរ និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដាសម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University